DIVISION OF DEVELOPMENTAL DISABILITIES

សេចក្តីជូនដំណឹងនៃការវាយតំលៃជំនួយសង្គ្រោះផ្នែកមើលថែទាំជំនួសម្តងម្តាល

NOTIFICATION OF WAIVER RESPITE CARE ASSESSMENT

យោងតាម:

<u>បត់ត្រង់នេះសំរាប់ស្រោមសំបុត្រមានបង្អួច</u>

សូមជំរាបមកដល់:

លិខិតនេះគឺជូនដំណឹងមកអ្នកចំពោះការផ្លាស់ប្តូរនូវរបៀបដែលនាយកដ្ឋានអភិវឌ្ឍន៍នៃភាពពិការ (DDD) កំណត់ចំនួនប្រាក់នៃការមើលថែទាំជំនួសម្តងម្តាលដែលមាននៅក្នុងជំនួយសង្គ្រោះផ្នែកសេវា Basic និង Basic Plus ។ ការប្តូរនឹងចាប់ប្រតិបត្តិនៅថ្ងៃទី 1 ខែកញ្ញាឆ្នាំ 2004 ។ នាយកដ្ឋាន DDD នឹងប្រើការវាយតំលៃថ្មីដើម្បីកំណត់ពីចំនួនប្រាក់នៃការមើលថែទាំម្តងម្តាលដែលអ្នកផ្តល់ការមើលថែទាំរបស់អ្នកអាចទទួល ។

- តំលៃនៃការមើលថែម្តងម្តាលនឹងមិនគិតទល់នឹងចំនួនប្រាក់កំរិតនៅក្នុងជំនួយសង្គ្រោះផ្នែកសេវា Basic និង Basic Plus ទេ ។ ការកំរិតសំរាប់ការមើលថែទាំម្តងម្តាលនឹងគឺជាចំនួនម៉ោងដែលបានកំណត់តាមការវាយតំលៃ ។
- ការវាយតំលៃនៃការមើលថែម្តងម្តាលនេះនឹងត្រូវធ្វើឡើងវិញយ៉ាងហោចណាស់ជារៀងរាល់ដប់ពីរ (12) ខែម្តង នៅពេលធ្វើការវាយតំលៃ/ការវាយតំលៃឡើងវិញនៃកម្មវិធី CARE ប្រចាំឆ្នាំរបស់អ្នកនិងផែនការនៃការមើលថែទាំ ។
- រហូតដល់ពេលការវាយតំលៃនៃកម្មវិធី CARE លើកក្រោយរបស់អ្នក ចំនួនប្រាក់នៃការមើលថែទាំម្តងម្តាលដែលមាននឹងនៅតែមានចំនួនដដែលដូចដែលបានអនុញ្ញាតឲ្យនៅក្នុងផែនការសេវាពេលបច្ចុប្បន្នរបស់អ្នក ។

<u>តើការវាយតំលៃត្រូវបានបំពេញយ៉ាងដូចម្តេច ?</u>

ការវាយតំលៃនៃជំនួយសង្គ្រោះផ្នែកមើលថែម្តងម្តាលគឺបានគ្រប់គ្រងដោយបុគ្គលិកក្រសួងនៅឱកាសធ្វើសម្ភាសន៍ផ្ទាល់ខ្លួនជាមួយអ្នក បើសិនជាអ្នកជ្រើសយកការមកធ្វើសម្ភាសន៍ ហើយនិងយ៉ាងហោចណាស់មានមនុស្សម្នាក់ផ្សេងទៀតដែលស្គាល់រូបអ្នកយ៉ាងច្បាស់ ដូចជាអ្នកផ្តល់ការមើលថែទាំជាគោលរបស់អ្នកជាដើម ។

<u>តើអ្នកណាផ្តល់ពត៌មានសំរាប់ការវាយតំលៃ ?</u>

ការឆ្លើយតបសំរាប់ការវាយតំលៃនៃការមើលថែម្តងម្តាលត្រូវតែជាមនុស្សធំ ដែលជាអ្នកស្គាល់គ្នាយ៉ាងច្បាស់ជាមួយអ្នក និងអាចផ្តល់ពត៌មានដែលត្រូវការដើម្បីបំពេញការវាយតំលៃ ដូចជាអ្នកផ្តល់ការមើលថែទាំជាគោលរបស់អ្នកជាដើម ។ អ្នកមិនអាចជាអ្នកឆ្លើយតបសំរាប់ការវាយតំលៃនៃការមើលថែម្តងម្តាលរបស់ខ្លួនឯងទេ ។

<u>តើម៉ោងដែលបានកំណត់ពីការវាយតំលៃធ្វើរបៀបណា ?</u>

ការឆ្លើយតបទៅនឹងការវាយតំលៃនៃការមើលថែម្តងម្តាលគឺប្តូរទៅជាចំនួនអតិបរមានៃចំនួនម៉ោងមើលថែម្តងម្តាលដែលអ្នកផ្តល់ការមើលថែទាំរបស់អ្នកត្រូវបានអនុញ្ញាតឲ្យទទួល ។ អ្នកអាចប្រើចំនួនម៉ោងមើលថែម្តងម្តាលឲ្យបានយ៉ាងច្រើនបំផុតតាមដែលអ្នកត្រូវការ រហូតដល់ចំនួនដែលចែកដោយឡែកសំរាប់ការមើលថែម្តងម្តាលដែលបានវាយតំលៃឲ្យ ។

<u>តើខ្ញុំនឹងដឹងចំនួនម៉ោងនៃការមើលថែម្តងម្តាលយ៉ាងណាដែលខ្ញុំមាន ?</u>

ការចែកដោយឡែកនៃការមើលថែទាំម្តងម្តាលនឹងត្រូវសរសេរទុកក្នុងផែនការនៃការមើលថែទាំរបស់អ្នកដាច់ដោយឡែក ដែលជាសេវាបានអនុញ្ញាតឲ្យ ។

<u>តើខ្ញុំអាចតវ៉ាចំពោះការកំណត់នៃចំនួនម៉ោងនេះបានឬទេ ?</u>

អ្នកមានសិទ្ធិសុំធ្វើសវនាការដោយយុត្តិធម៌ដោយសំអាងលើលទ្ធផលនៃការវាយតំលៃជំនួយសេវាគ្រោះជំនួសម្តងម្តាល ។ សិទ្ធិធ្វើសវនាការដ៏យុត្តិធម៌ទឹងត្រូវផ្តល់ជូនជាចំណែកមួយនៃផែនការ POC, ដោយសារដំណើរការនេះកំណត់ចំនួននៃសេវាដែលមាននៅក្នុងផែនការ POC ។

សូមទូរស័ព្ទមក បើសិនជាអ្នកមានសំនួរឬកង្វល់នានា ។

ឈ្មោះនាយកគ្រប់គ្រងសំណុំរឿងធនធាន	មុខងារ
លេខទូរស័ព្ទ (រួមទាំងលេខតំបន់)	អាសយដ្ឋានអ៊ីមែល

INSTRUCTIONS FOR RESPITE ASSESSMENT NOTIFICATION

When do I use this form?
You send this letter to the client at least 60 days prior to their annual CARE assessment and POC meeting.

Who do I send this letter to?
This notification letter is only sent to individuals in the Basic and Basic Plus Waivers.

Do I send this form out to the client more than once?
No, this is a one-time only notification to the client advising them of the change in the way DDD determines the amount of respite available to the client's caregiver.

Do I send this letter to someone who does not express a current desire for respite care?
Yes, even though the individual may not express a current need for respite care, this assessment should be completed in conjunction with the CARE assessment so that an individual's assessed personal care and respite care needs can be met at any time, and to ensure that the individual is able to meet the minimum waiver eligibility requirement of receiving a monthly waiver service.